**សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)**

Cambodian Water Supply Association (C.W.A)

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ និងតម្លើងម៉ូទ័របូមទឹកអណ្តូងខួង ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) អង្គការយូនីសេហ្វ (UNICEF) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសេកគង់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតប៉េងហុង ស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បាននឹងកំពុងអនុវត្តគម្រោង «**បង្កើននូវភាពធនសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរស់នៅក្នុងតំបន់ដែលបានរងគ្រោះពីគ្រោះធម្មជាតិ ដែលមិនទាន់មានបណ្តាញទឹកស្អាត**» ក្រោមជំនួយថវិកាពីអង្គការយូនីសេហ្វ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សមាគមមានកិត្តិយសសូមអញ្ជើញក្រុមហ៊ុន ឬអ្នកម៉ៅការដែលមានបទពិសោធន៍ក្នុងការតម្លើងម៉ូទ័របូមទឹកពីអណ្តូងខួង ដោយប្រើថាមពលពន្លឺព្រះអាទិត្យ(ប្រព័ន្ធសូឡា) ក្នុងព្រះរាជាណាចក្រកម្ពុជា ដាក់ពាក្យស្នើសុំផ្គត់ផ្គង់សេវាកម្ម និងបំពាក់បរិក្ខារម៉ូទ័របូមទឹកដោយប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ(ប្រព័ន្ធសូឡា) ជូនដល់ប្រតិបត្តិករទឹកស្អាតទាំងពីរខាងលើ ដូចមានក្នុងតារាងព័ត៌មាន និងលក្ខខណ្ឌលម្អិតដូចខាងក្រោម៖

| ល.រ | បរិយាយពីសម្ភារ | លក្ខណៈសម្ភារ | ជម្រៅអណ្តូង(m) | ចំនួន |
|---|---|---|---|---|
| 1 | ម៉ូទ័របូមទឹកអណ្តូង និងប្រព័ន្ធសូឡា | 5ph-10hp,,Q=2 -3m$^3$/h | 50 m ទៅ100 m | 7 |
| 2 | ប្រព័ន្ធខ្សែភ្លើង ខ្សែកាប និងប្រអប់ភ្លើង | ខ្សែកាបសម្រាប់ចាប់ម៉ូទ័របូមទឹកពីអណ្តូង និងខ្សែភ្លើងតម្លើងប្រព័ន្ធ | 50 m ទៅ100 m | 7 |
| 3 | បំពង់បូមទឹកផៅ និងគ្រឿងតណភ្ជាប់ | បំពង់នាំទឹកពីម៉ូទ័រឡើងមកដល់មាត់អណ្តូង និងគ្រឿងតំណផ្សេងៗ | 50 m ទៅ100 m | 7 |

1. រាល់ឯកសារដេញថ្លៃរួមមាន៖ ពាក្យសុំដេញថ្លៃ និងឯកសារភ្ជាប់នានា ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកការិយាល័យសមាគម រៀងរាល់ម៉ោងធ្វើការឲ្យបានមុនថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។ រាល់ឯកសារដេញថ្លៃទាំងឡាយដែលបានដាក់ក្រោយកាលបរិច្ឆេទ មិនត្រូវបានពិចារណាឡើយ។
2. ក្រុមហ៊ុនដែលទទួលបានជោគជ័យ ត្រូវរៀបចំតម្លើងម៉ូទ័របូមទឹកអណ្តូងខួង ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ (ប្រព័ន្ធសូឡា) ជូនស្ថានីយផ្គត់ផ្គង់ទឹកស្អាតទាំងពីរខាងលើ យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២**។
3. ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ អាចមកទទួលឯកសារដេញថ្លៃនៅសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយឥតគិតថ្លៃ ដែលមានអាសយដ្ឋានដូចរៀបរាប់ខាងក្រោម ឬទាញយកពីគេហទំព័រ www.cwa.org.kh ឬទំព័រហ្វេសប៊ុក Cambodian Water Supply Association និង អ៊ីមែល៖ info@cwa.org.kh។ ***រាល់តម្លៃត្រូវបូកបញ្ចូលពន្ធលើតម្លៃបន្ថែម(VAT) ឬបញ្ជាក់ពីការបង់ពន្ធកាត់ទុក (Withholding Tax) ក្នុងករណីពុំមាន(VAT)***។
4. ការបើកស្រោមសំបុត្រដេញថ្លៃនឹងត្រូវប្រព្រឹត្តឡើងជាសាធារណៈនៅការិយាល័យសមាគម នាថ្ងៃ**ទី២២ ខែវិច្ឆកា ឆ្នាំ២០២១** វេលាម៉ោង ២:០០រសៀល ដែលមានអ្នកចូលរួមមកពីតំណាងស្ថានីយផ្គត់ផ្គង់ទឹកស្អាត តំណាង អង្គការ

5. យូនីសេហ្វ តំណាងមកពីក្រសួងឧសហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ និងតំណាងក្រុមហ៊ុនដាក់ដេញថ្លៃ។
6. **អាសយដ្ឋានទំនាក់ទំនង និងដាក់ពាក្យ៖** មជ្ឈមណ្ឌលភ្នំពេញ អគារF  ជាន់ទី២ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញឬ ទូរស័ព្ទលេខ៖ ០១២ ៥៩៤ ៧៦០ ឬ ០១៧ ៧៩៩ ៣៣៧ ឬ ០៧០ ៧៩៩ ៣៣៧ ឬ ០៩៧៧ ១៧៩ ៩៤៣។ អ៊ីមែល៖ info@cwa.org.kh គេហទំព័រ៖ www.cwa.org.kh